# បញ្ជីផែនការមើលសុវត្ថិភាពនៃភ្លើងឆេះផ្ទះ

Fact Sheet 10 – Community Risk Management. Revised 28/09/2004 - Khmer

- NSW FIRE BRIGADES
- NSW RURAL FIRE SERVICE
- ACT FIRE BRIGADE
- ACT RURAL FIRE SERVICE

## ហេតុការណ៍

ឆ្នាំមុន ផ្ទះចំនួន ១៨៩ ខ្នងត្រូវបានខូចខាតជាដំណាំក្នុងពេលភ្លើងឆេះដែលប្រភពភ្លើងឆេះឡើងគឺពីកន្លែងដុតភ្លើងកំដៅ, គ្រឿងកំដៅ និងគ្រឿងដុតកំដៅទឹកក្តៅ, ភ្លើងឆេះផ្ទះចំនួន ៩៧៨ ខ្នងគឺឆេះមកពីជើងក្រាន, ឡ, ឆ្នាំងសំរាប់ចំពង ហើយនិងប្រដាប់ដាំស្លងទៀត ហើយនិងភ្លើងឆេះចំនួន ៥៩២ ដែលបណ្តាលមកពីប្រពន្ធ័គ្រឿងអគ្គិសនីខូចដូចជាឆ្លងភ្លើង (short circuits) និងតំណាចរន្ត (plug) ខូចជាដើម ។ *(ស្ថិតិត្រឹមត្រូវនាថ្ងៃទី១៧/០៤/០៣)*

## តើលោកអ្នកមានសុវត្ថិភាពនៃភ្លើងឆេះនៅផ្ទះឬទេ?

កងរំលត់ភ្លើងរដ្ឋ NSW ផ្តល់នូវឱវាទអំពីបញ្ជីផែនការមើលសុវត្ថិភាពដ៏សាមញ្ញនេះ ដើម្បីជួយរក្សាសុវត្ថិភាពនៅពេលភ្លើងឆេះផ្ទះលោកអ្នក ។

- ☐ ការដាក់គ្រឿងឲ្យសញ្ញាពេលមានផ្សែង (smoke alarms) ឲ្យបានគ្រប់គ្រាន់ហើយនិងធ្វើតេស្តវាជាញឹកញាប់ គឺជាជំហានទីមួយនៅក្នុងផែនការសុវត្ថិភាពនៃភ្លើងឆេះផ្ទះរបស់លោកអ្នក ។
- ☐ សរសេរផែនការគេចចេញ ក្រែងលោភ្លើងឆេះ ហើយហាត់តាមជាញឹកញាប់គឺជាជំហានទីពីរ ។
- ☐ សូមធ្វើឲ្យប្រាកដថាកូនសោនៃទ្វារដែលចាក់ទាំងអស់អាចរកបានដោយងាយក្រែងលោលោកអ្នកត្រូវការគេចចេញ ។
- ☐ សូមកុំទុកការដាំស្ល ឬអណ្តាតភ្លើងឯទៀតដូចជាទៀន ឬគ្រឿងដុតប្រេងដោយគ្មានអ្នកចាំមើលឲ្យសោះ ។
- ☐ សូមសំអាតតម្រងកំទេចនៃម៉ាស៊ីនធ្វើឲ្យស្ងួតម្តងឬរាល់ពេលលោកអ្នកប្រើវា ។
- ☐ សូមកុំពិសារបារីនៅលើគ្រែហើយមានការប្រយ័ត្នប្រយែងថែមទៀត ប្រសិនបើពិសារស្រានៅពេលពិសារបារី ។
- ☐ នៅរដូវត្រជាក់ សូមមានការប្រយ័ត្នប្រយែងថែមទៀតពេលប្រើគ្រឿងដុតកំដៅ, ភួយអគ្គិសនី ឬដុតភ្លើងចំហរ ។
- ☐ សូមកុំប្រើកន្លែងដោតចរន្តឲ្យហួសកម្លាំងហើយបិទគ្រឿងអគ្គសនីពេលមិនប្រើវា ។
- ☐ សូមទុកដែកកេះនិងឈើគូសឲ្យឆ្ងាយពីក្មេងហើយអប់រំគេថា វាជារបស់ប្រើ *"មិនមែនល្បែងលេងទេ"* ដែលសំរាប់តែប្រើដោយមនុស្សធំដែលមានការទទួលខុសត្រូវប៉ុណ្ណោះ ។
- ☐ ប្រសិនបើលោកអ្នកមានយានដ្ឋានឬ រោង សូមចងចាំថាការទុកដាក់ជាតិគីមីនិងសាំងត្រូវការការប្រយ័ត្នប្រយែងថែមទៀត ហើយ ជានិច្ចជាកាល, ពេលចាក់សាំងម៉ាស៊ីនកាត់ស្មៅ, ម៉ាស៊ីនកាត់សំអាតគែម ។ល។ សូមចាក់នៅពេលវាត្រជាក់ហើយនៅទីចំហរផង ។
- ☐ ប្រសិនបើលោកអ្នកមានគ្រឿងអាំងសាច់ប្រើឧស្ម័ន, អគ្គិសនី ឬឧស សូមឆែកមើលជានិច្ចតើវាអាចប្រើបានដោយសុវត្ថិភាពទេ មុនដុតហើយនិងនៅពេលប្រើត្រូវតែមានការមើលខុសត្រូវដោយមនុស្សធំជានិច្ច ។ (សូមអានក្រដាស់ហេតុការណ៍លេខ ១៦ ស្តីពីសុវត្ថិភាពនៃការអាំងសាច់ទូទៅ)
- ☐ ប្រសិនបើលោកអ្នករស់នៅកន្លែងដែលធ្លាប់មានភ្លើងឆេះព្រៃ សូមរក្សាដីធ្លាជុំវិញផ្ទះលោកអ្នកកុំឲ្យមានស្លឹកឈើនិងសំរាមឯទៀតហើយសូមមេត្តាកុំភ្លេចសំអាតទទឹកជាញឹកញាប់ផងដែរ ។

**ចំពោះពត៌មានថែមទៀត សូមទាក់ទងស្ថានីយ៍រំលត់ភ្លើង ឬមជ្ឈមណ្ឌលត្រួតត្រាភ្លើងតាមតំបន់លោកអ្នក ។**

**ឬ មើលវែបសៃ: www.fire.nsw.gov.au www.rfs.nsw.gov.au or www.esa.act.gov.au**

## ចំណុចសំខាន់ៗនៃសុវត្ថិភាពភ្លើងឆេះ

- សូមចងចាំថាផ្សែងពីភ្លើងឆេះនឹងធ្វើឲ្យលោកអ្នកច្របូកច្របល់ហើយលោកអ្នកពុំអាចមើលឃើញនៅក្នុងផ្សែងទេ ។
- នៅពេលទទួលទានដំណេក, លោកអ្នកនឹងពុំធុំក្លិនផ្សែងទេ ហើយតាមការពិតវានឹងធ្វើឲ្យលោកអ្នកដេកលក់ស៊ុបទៅទៀតផង ។
- ប្រសិនបើលោកអ្នកបានគេចផុតពីភ្លើងឆេះផ្ទះ, សូមចងចាំថាកាលណាលោកអ្នកគេចផុតហើយ សូមនៅក្រៅ ហើយទូរស័ព្ទលេខ 000 ។
- គ្រឿងដុតកំដៅដោយប្រេង, ឧស្ម័ន ឬឧស ប្រហែលជាត្រូវការការថែទាំប្រចាំឆ្នាំ ។
- សូមប្រើ (fuse) តាមកំរិតដែលគេឲ្យឱវាទហើយសូមដាក់កុងតាក់អគ្គិសនីសំរាប់សុវត្ថិភាពមួយ (electrical safety switch) ។
- សុវត្ថិភាពនៃភ្លើងឆេះផ្ទះជាការសំខាន់ណាស់ចំពោះគ្រួសារទាំងអស់ ហើយនិងការត្រៀមលក្ខណៈជាមុនអាចការពារពីសោកនាដកម្មបាន ។

**ក្នុងពេលអាសន្ន សូមទូរស័ព្ទលេខ 000**